របៀបសិក្សាច្បាប់

HOW TO STUDY LAW

សំគាល់÷

អត្ថបទចងក្រងឡើងជាពិសេសសម្រាប់និស្សិតច្បាប់ឆ្នាំទី១។ ជំពូកទី១និងជំពូកទី២នៅក្នុងអត្ថបទនេះជាអត្ថបទបកប្រែក្រៅផ្លូវការដោយបានដកស្រង់និងប្រែសម្រួលជាភាសាខ្មែរពីសៀវភៅដើមភាសាជប៉ុន លោក YANAGA Masao「法律学習マニュアル How to Study Law」បោះពុម្ពលើកទី៤ ឆ្នាំ២០១៦។

អ្នកសម្រួលភាសាខ្មែរ÷ ជា សៀវម៉ី, ម៉ែន គង្គា, ហួច ម៉េងហួរ
ចេញផ្សាយដំបូង មីនា ឆ្នាំ២០២០

មាតិកា

ជំពូកទី ១ 1

អំពីការសិក្សាផ្នែកនីតិសាស្ត្រ 1

១-១ ការសិក្សាត្រឹមកម្រិតវិទ្យាល័យ និង ការសិក្សាផ្នែកនីតិសាស្ត្រ 2

១. ចម្លើយត្រឹមត្រូវមានច្រើន 2

២. ភាពប្រហាក់ប្រហែលនឹងការសិក្សាភាសាបរទេសដែរ 2

៣. ចំណេះដឹងពីវិទ្យាល័យមិនឥតប្រយោជន៍ទេ 2

១-២ ការពិចារណាឲ្យលម្អិត 3

១. ការពិចារណាលក្ខណៈរូបិយ និង អរូបិយ 3

២. ដើម្បីអាចគិតលក្ខណៈរូបិយបានត្រូវធ្វើបែបណា? 4

១-៣ គំនិតបែបច្បាប់ (Legal Mind) គឺជាអ្វី? 5

១. ភាពសាំញ៉ាំនៃ Legal Mind 5

២. រៀនឆ្ងល់ 5

៣. ការត្រិះរិះបែបរិះគន់ 6

៤. មើលឲ្យឃើញអំពីចំនុចសំខាន់ 6

១-៤ ចំនុចប្រសព្វនៃមុខវិជ្ជាដែលប្រហាក់ប្រហែលគ្នា 7

១. សមត្ថភាពរបស់អ្នកច្បាប់ 7

២. ភាពសមស្របនៃប្រព័ន្ធច្បាប់កំពុងដំណើរការ 7

១-៥ មាត្រាច្បាប់ជាចំនុចចាប់ផ្តើម 8

១. ច្បាប់ជា “បច្ចេកទេសនៃការពន្យល់ឲ្យគេយល់ស្របតាម” 8

២. ភាពត្រឹមត្រូវនៃសេចក្តីសន្និដ្ឋាននិងមាត្រាច្បាប់ 8

៣. “ផ្លូវទៅកាន់សេចក្តីសន្និដ្ឋាន” និងមាត្រាច្បាប់ 9

៤. អ្វីទៅជាការបកស្រាយបង្រួម? 9

៥. អ្វីទៅជាការបកស្រាយពង្រីក? 10

៦. អ្វីទៅជាការអនុវត្តប្រដូច? 10

៧. អ្វីទៅជាការបកស្រាយបញ្ច្រាស? 10

ជំពូកទី២ 12

សិក្ខាប័នច្បាប់ 12

២-១. គុណសម្បត្តិនៃស្តាប់សិក្ខាប័នច្បាប់ 13

២-២. របៀបជ្រើសរើសមុខវិជ្ជាច្បាប់ 14

២-៣. របៀបស្តាប់គ្រូបង្រៀន 18

១. ការរៀនត្រៀមមុន និង ការរំលឹកមេរៀន តើមួយណាល្អជាង? 18

២. របៀបស្តាប់ក្នុងមុខវិជ្ជាច្បាប់ 18

២-៤. រៀនសូត្រក្រៅពីម៉ោងរៀន 20

១. សុំជំនួយពីគ្រូឬរៀមច្បងគឺជាជម្រើសលឿន 20

២. មិនមែនទៅរៀនគ្រាន់តែស្តាប់គ្រូប៉ុណ្ណោះទេ 20

៣. របៀបសួរសំនួរ 21

៤. ស្វែងរកជំនួយដើម្បីលូតលាស់ទៅមុខទៀត 21

៥. ស្វែងរកជំនួយពីរៀមច្បង 22

ជំពូកទី៣ 23

បញ្ជីសៀវភៅសម្រាប់និស្សិតច្បាប់អានជាមូលដ្ឋានគ្រឹះ 23

៣-១. នីតិសាធារណៈ 24

៣-២. នីតិឯកជន 24

៣-៣. ប្រវិត្តសាស្ត្រ នយោបាយ ទស្សនវិជ្ជា 24

៣-៤. វិធីសាស្ត្រស្រាវជ្រាវ 24

៣-៥. អត្ថបទពិចារណា 25

ជំពូកទី ១

អំពីការសិក្សាផ្នែកនីតិសាស្ត្រ

១-១ ការសិក្សាត្រឹមកម្រិតវិទ្យាល័យ និង ការសិក្សាផ្នែកនីតិសាស្ត្រ

១. ចម្លើយត្រឹមត្រូវមានច្រើន

ការរៀននៅវិទ្យាល័យ និង ការរៀនច្បាប់នៅកម្រិតឧត្តមសិក្សា មានចំនុចខុសប្លែកពីគ្នាជាច្រើន។ ចំនុចខុសចម្បងទី១ គឺថាការរៀនច្បាប់នៅកម្រិតឧត្តមសិក្សា "ចម្លើយត្រឹមត្រូវ" នឹងមានច្រើន។ ដោយឡែកកាលពីរៀននៅវិទ្យាល័យវិញគឺជាការរៀនដើម្បីប្រលង ភាគច្រើនចម្លើយត្រឹមត្រូវតែមួយប៉ុណ្ណោះ។ ចំពោះផ្នែកនីតិសាស្ត្រវិញ មានទ្រឹស្តីនិងយុត្តិសាស្ត្រជាច្រើនដែលសុទ្ធតែមានបែបផែនវិចារណ៍រៀងៗគ្នា។ ដូច្នេះ ក្នុងនាមជាអ្នកអាន និស្សិតត្រូវចេះពិចារណាថាខ្លួននឹងយល់ស្របតាមគំនិតណា។ ម្យ៉ាងទៀត និស្សិតត្រូវមានសមត្ថភាពបកស្រាយដោយឈរលើគំនិតណាមួយ។

២. ភាពប្រហាក់ប្រហែលនឹងការសិក្សាភាសាបរទេសដែរ

ទោះបីជាមានភាពខុសគ្នាពីការរៀននៅវិទ្យាល័យក៏ដោយ ក៏នៅមានចំនុចខ្លះនិស្សិតត្រូវយកចំណេះដឹងពីវិទ្យាល័យមកប្រើប្រាស់ដែរ។ ការរៀនច្បាប់ មានភាពស្រដៀងនឹងរៀនភាសាបរទេស។ ការស្វែងយល់ឲ្យបានត្រឹមត្រូវអំពីវាក្យស័ព្ទច្បាប់ជារឿងដ៏សំខាន់បំផុត។ ភាសាប្រចាំថ្ងៃនិងវាក្យស័ព្ទបច្ចេកទេសច្បាប់ មានភាពខុសគ្នាទោះជាតិចក្តីឬច្រើនក្តី។ វាក្យស័ព្ទច្បាប់ខ្លះគឺជាភាសាហួសសម័យឬគ្រាមភាសា។ ចំពោះការសិក្សាភាសាអង់គ្លេសវិញ នៅពេលជួបពាក្យមិនចេះ អ្នកត្រូវបើកវចនានុក្រម។ ដូច្នេះ នៅពេលរៀនច្បាប់ អ្នកគួរបន្តរៀនជាមួយនឹងការបើកវចនានុក្រមច្បាប់ផង។ ម្យ៉ាងទៀត ក្នុងការអភិវឌ្ឍផ្នែកភាសាឲ្យបានឆាប់រហ័ស គឺត្រូវយកពាក្យពេចន៍ទាំងនោះមកប្រើក្នុងបរិស្ថានដែលគេប្រើប្រាស់ឲ្យបានញឹកញាប់ ចំណែកឯការរៀនច្បាប់វិញក៏ដូចគ្នាដែរ។

៣. ចំណេះដឹងពីវិទ្យាល័យមិនឥតប្រយោជន៍ទេ

មូលដ្ឋាននៃការរៀនច្បាប់ គឺអាស្រ័យលើការអានសៀវភៅ។ ដូច្នេះ និស្សិតត្រូវមានសមត្ថភាពយល់ដឹងអំពីភាសាជាតិ។ ជាពិសេស ឃ្លាដែលសរសេរក្នុងសាលក្រមឬសាលដីកា និស្សិតត្រូវស្វែងយល់ឲ្យបានត្រឹមត្រូវអំពីទម្រង់ ដូចជាទម្រង់បដិសេធជាន់គ្នា (បដិសេធនិងបដិសេធ) ព្រមទាំងប្រធានកិរិយាសព្ទ និងកម្មបទ។ ម្យ៉ាងទៀត ការពន្យល់ដោយការគូសជារូបភាពដែលអ្នកបានរៀននៅវិទ្យាល័យ

និងការបកស្រាយឲ្យបានសមហេតុផលក៏មានចំនុចស្រដៀងគ្នាដែរ។ មិនថារៀននៅវិទ្យាល័យឬការរៀនច្បាប់ទេ អ្នកត្រូវប្រើបច្ចេកទេសយ៉ាងណាធ្វើឲ្យភាគីម្ខាងទៀតយល់ស្របតាមអ្នក។ ដោយឡែកចំពោះការរៀនច្បាប់ មានចំនុចត្រូវវិនិច្ឆ័យដោយផ្អែកលើហេតុផលសមស្របណាមួយ ដូច្នេះការរៀនច្បាប់មានភាពស្មុគស្មាញជាងកាលពីរៀននៅវិទ្យាល័យ ។

បន្ថែមពីនេះ ប្រវត្តិសាស្ត្រ នយោបាយ និងសេដ្ឋកិច្ចវិញ នឹងក្លាយទៅជាសេចក្តីផ្តើមនៃការសិក្សាច្បាប់ ដោយសារច្បាប់គឺជាសមិទ្ធផលនៃប្រវត្តិសាស្ត្រដែលបានបង្កើតឡើងផ្អែកលើបរិបទនៃសង្គម និងសេដ្ឋកិច្ចផ្សេងៗជាច្រើន និងបានវិវត្តន៍អស់ពេលរាប់សិបខែឆ្នាំ។ ហេតុនេះមុខវិជ្ជាសិក្សាសង្គមនៅកម្រិតវិទ្យាល័យ ក៏មានទំនាក់ទំនងជាមួយនឹងការរៀនច្បាប់ផងដែរ។ ឧទាហរណ៍ នៅពេលដែលរៀនមុខវិជ្ជានីតិរដ្ឋធម្មនុញ្ញ និស្សិតនឹងឃើញមានពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រពិភពលោក ប្រវត្តិនយោបាយ និងប្រវត្តិទស្សនៈផងដែរ។ ម្យ៉ាងវិញទៀត បើពិចារណាផ្អែកលើប្រវត្តិសាស្ត្រ នឹងធ្វើឲ្យនិស្សិតអាចបន្ថែមនូវសមត្ថភាពបកស្រាយបានល្អផងដែរ។

១-២ ការពិចារណាឲ្យលម្អិត

១. ការពិចារណាលក្ខណៈរូបិយ និង អរូបិយ

និស្សិតនឹងមានអាម្មណ៍ថាការរៀនច្បាប់មិនស្ថិតនៅជិតខ្លួនយើងសោះ។ នៅក្នុងសៀវភៅមេរៀនភាគច្រើនអ្នកនិពន្ធសរសេរឡើងជាលក្ខណៈអរូបិយ។ រីឯ ច្បាប់ត្រូវបានតាក់តែងឡើងដោយផ្អែកលើបទពិសោធន៍ជាច្រើន។ នៅក្រោយបទពិសោធន៍ទាំងនោះ គឺច្បាស់ជាមានឫសគល់ដែលជាអង្គហេតុ។ ចំពោះទ្រឹស្តីវិញ ត្រូវបានអភិវឌ្ឍដោយព្យាករណ៍អំពីព្រឹត្តិការណ៍ជាក់ស្តែង។

នៅពេលធ្វើការពិភាក្សាបញ្ហាដែលមានលក្ខណៈអរូបិយ អ្នកចាំបាច់ត្រូវយកបញ្ហានោះមកស្រមៃនិងគូសឲ្យចេញជាលក្ខណៈរូបិយដើម្បីអាចយល់បាន។ ដូចគ្នានេះផងដែរ នៅពេលដែលអ្នកជួបនឹងរឿងក្តីជាក់ស្តែង អ្នកក៏ចាំបាច់ធ្វើវាឲ្យក្លាយជាលក្ខណៈអរូបិយដើម្បីអាចយកមកផ្ទឹមជាមួយនឹងមាត្រាក្នុងច្បាប់។ មានន័យថា មាត្រាក្នុងច្បាប់ត្រូវបានសរសេរឡើងក្រោមប្រយោគលក្ខណៈអរូបិយខ្លាំងដើម្បី

អាចយកទៅអនុវត្តបានទូទៅ។ ដោយឡែក ចំពោះរឿងក្តីជាក់ស្តែងគឺមានលក្ខណៈរូបិយខ្លាំងវិញ។ អ្នកច្បាប់ត្រូវបង្ហាញជំនាញក្នុងការធ្វើឲ្យមាត្រានិងរឿងក្តីដែលមានលក្ខណៈរូបិយនោះផ្សារភ្ជាប់គ្នាបាន។

២. ដើម្បីអាចគិតលក្ខណៈរូបិយបានត្រូវធ្វើបែបណា?

មូលហេតុដែលធ្វើឲ្យយើងមានអារម្មណ៍ថា ការពិភាក្សាដេញដោលនៅក្នុងការរៀនច្បាប់ស្មុគស្មាញ គឺដោយសារយើងមិនបានយកវាទៅភ្ជាប់នឹងបទពិសោធន៍ជាក់ស្តែង។ ប្រសិនបើអ្នកមានបទពិសោធន៍ដូចជា ការជួលផ្ទះ នោះអ្នកនឹងអាចយល់អំពីបទប្បញ្ញត្តិមួយចំនួននៅក្នុងក្រមរដ្ឋប្បវេណីស្តីពីការលក់ទិញឬការជួលបាន។

ម្យ៉ាងទៀត អ្នកមិនអាចដកពិសោធន៍ជាក់ស្តែងឲ្យបានគ្រប់ចំនុចដែលជាកម្មវត្ថុនៅក្នុងច្បាប់ទាំងអស់នោះទេ ហេតុនេះអ្នកចាំបាច់ត្រូវប្រើវិធីផ្សេងជាជំនួយបន្ថែមដូចជា៖

វិធីទី១ គឺការទៅមើលផ្ទាល់និងស្តាប់។ អ្នកអាចស្តាប់សវនាការបាន។ ករណីសវនាការអំពីរឿងក្តីព្រហ្មទណ្ឌ អ្នកអាចដឹងលំហូរទាំងមូលនៃរឿងក្តីបានត្រឹមកម្រិតមួយ។ ប៉ុន្តែ គួរឲ្យស្តាយ ករណីរឿងក្តីរដ្ឋប្បវេណីគ្រប់ការអះអាងរបស់ភាគីបណ្តឹងត្រូវបានដាក់ទៅតុលាការជាទម្រង់លិខិត ក៏មិនមានអានឲ្យស្តាប់ផ្ទាល់ដែរ ដូច្នេះទោះបីជាអ្នកទៅស្តាប់សវនាការក៏ដោយ ក៏អ្នកមិនអាចយល់សវនាការនោះទេ។ ម្យ៉ាងទៀត ការសាកសួរពីមិត្តភក្តិដែលជាអ្នកច្បាប់ឬអ្នកដែលកំពុងធ្វើការនៅក្នុងក្រុមហ៊ុន ថាតើច្បាប់ដើរតួនាទីបែបណា? ឬផ្តល់ប្រយោជន៍អ្វីខ្លះចំពោះការដោះស្រាយវិវាទ ក៏ជាវិធីមួយល្អដែរ។

វិធីទី២ គឺការអានយុត្តិសាស្ត្រដែលបានឆ្លុះបញ្ចាំងក្នុងករណីសិក្សាជាក់ស្តែង។ អ្នកនឹងអាចដឹងថា តើករណីជាក់ស្តែងនិងទ្រឹស្តីច្បាប់ឆ្លើយតបគ្នាយ៉ាងដូចម្តេចខ្លះ?

វិធីទី៣ គឺការប្រើសៀវភៅមេរៀនច្បាប់ដែលបានសរសេរលម្អិត។ ក្នុងសៀវភៅមេរៀនដែលល្អគឺជាសៀវភៅដែលបានលើកឡើងអំពីអង្គហេតុនានា និងមានពន្យល់បកស្រាយយ៉ាងលម្អិតដោយប្រើរូបភាព រូបថត ព្រមទាំងមានបង្ហាញពីលក្ខណៈសមហេតុផលរបស់ច្បាប់ផងដែរ។ សង្ឃឹមថាអ្នកនឹងបានស្គាល់អ្នកនិពន្ធល្អៗច្រើន។ សូមមើលបញ្ជីសៀវភៅនៅឧបសម្ព័ន្ធសម្រាប់និស្សិតច្បាប់អានជាមូលដ្ឋាននៅជំពូកទី៣។

១-៣ គំនិតបែបច្បាប់ (Legal Mind) គឺជាអ្វី?

១. ភាពសាំញ៉ាំនៃ Legal Mind

គោលបំណងនៃការអប់រំច្បាប់មិនមែនគ្រាន់តែផ្តល់ចំណេះដឹងច្បាប់ "Legal Knowledge" នោះទេ តែវាជាការអប់រំដែលបង្កើតឲ្យមានចិត្តគំនិតបែបច្បាប់ "Legal Mind"។

ពាក្យថា "Legal Mind" ត្រូវបានយកមកប្រើតាមទម្រង់និងក្រោមអត្ថន័យផ្សេងៗ។ អត្ថន័យទាំងនោះអាចប្រែប្រួលទៅតាមសមត្ថភាពបញ្ជាក់ឲ្យបានច្បាស់នូវទឡ្ហីករណ៍រៀកញែក ដូចជា សមត្ថភាពក្នុងការពិចារណាអំពីថាតើវាស្ថិតនៅទីតាំងណាមួយក្នុងប្រព័ន្ធច្បាប់ទាំងមូល? បន្ទាប់មកធ្វើការដោះស្រាយ និង សមត្ថភាពក្នុងការស្វែងយល់អំពីស្ថានភាពនៃព្រឹត្តិការណ៍ជាដើម។ នៅក្នុងដំណាក់កាលវិនិច្ឆ័យឬចេញសេចក្តីសម្រេច គេត្រូវពឹងផ្អែកលើអ្នកដែលធ្លាប់រៀនច្បាប់ថា ពីព្រោះអ្នកច្បាប់អាចវិនិច្ឆ័យប្រកបដោយភាពត្រឹមត្រូវ ហើយមានលក្ខណៈរួម ព្រមទាំងអាចមើលឲ្យសព្វជ្រុងជ្រោយ។

ប៉ុន្តែ ចំនុចស្នូលនៃ Legal Mind គឺជាសមត្ថភាពពិចារណាអំពីកត្តាផ្សេងៗបណ្តើរ ហើយយកមកគិតខ្លួនឯង ព្រមទាំងធ្វើឲ្យអ្នកដទៃអាចទទួលយកការបកស្រាយរបស់អ្នក។ Legal Mind មិនមែនជាសមត្ថភាពចងចាំវិធានច្បាប់នោះទេ តែវាគឺជាសមត្ថភាពក្នុងការយកទ្រឹស្តីផ្សេងៗនិងគំនិតរបស់ក្នុងអ្នកដទៃមកយោងជាមូលដ្ឋាន ហើយធ្វើឲ្យអ្នកដទៃអាចយល់ស្របតាមបាន។

២. រៀនឆ្ងល់

សំណួរសួរថា "ហេតុអ្វី" គឺមានសារៈសំខាន់បំផុតក្នុងការរៀនច្បាប់។ ដើម្បីសន្និដ្ឋានចំពោះបញ្ហាជាក់ស្តែងបាន អ្នកត្រូវបង្ហាញច្បាស់លាស់ថា ហេតុអ្វីបានជាកើតរឿងបែបហ្នឹង? ឬហេតុអ្វីបានជាត្រូវការបែបនេះ? ហេតុដូច្នេះ ពេលអ្នកអានអត្ថបទឬស្តាប់បទបង្ហាញ អ្នកគួរតែបន្តការរៀននោះដោយភ្ជាប់ជាមួយនឹងសំណួរ "ហេតុអ្វី" ជានិច្ច។ ការធ្វើបែបនោះនឹងធ្វើឲ្យប្រសិទ្ធភាពនៃការសិក្សាច្បាប់របស់អ្នកនឹងកើនឡើងជាលំដាប់។

៣. ការត្រិះរិះបែបរិះគន់

នៅសតវត្សទី១៨ មាននិស្សិតវ័យក្មេងម្នាក់ បានចូលស្តាប់បទបង្ហាញរបស់លោក Black Stone នីតិវិទូនៃប្រទេសអង់គ្លេស។ និស្សិតនោះមិនបានកត់ត្រាអ្វីទាំងអស់។ មានមិត្តម្នាក់បានសួរ អំពីមូលហេតុដែលគាត់មិនកត់ត្រា ពេលនោះគាត់បានឆ្លើយថា "មកពីខ្ញុំកំពុងគិតថា តើបទបង្ហាញរបស់គ្រូត្រឹមត្រូវទេ? ខ្ញុំគ្មានពេលទំនេរដើម្បីកត់ត្រាទេ"។ និស្សិតម្នាក់នោះគឺលោក Jeremy Bentham ដែលល្បីខាងទ្រឹស្តីប្រយោជន៍និយម (Utilitarianism)។

ការរៀនច្បាប់ចាំបាច់បំផុតត្រូវមានអត្តចរិតបែបរិះគន់។ ការចាប់ផ្តើមនៃ Legal Mind គឺការធ្លល់លើចំណេះដឹងដែលបានលើកឡើងស្រាប់ៗតាមរយៈបទបង្ហាញគ្រូឬសៀវភៅ រួចយកមកគិតដោយខ្លួនឯង។

ភាគច្រើន អ្នកអានធាប់ជឿលើខ្លឹមសារក្នុងសៀវភៅឬបទបង្ហាញរបស់គ្រូល្បីៗ។ ដោយឡែក ខ្លឹមសារសៀវភៅឬពាក្យសម្តីរបស់គ្រូល្បីៗនោះ ក៏មិនប្រាកដថាមានភាពត្រឹមត្រូវទាំងស្រុងទេ។ មិនតែប៉ុណ្ណោះ បើនិយាយពីយុត្តិសាស្ត្រតុលាការវិញ ជាពិសេសសាលដីកាតុលាការកំពូល ប្រហែលជាធ្លាប់មាននិស្សិតខ្លះយល់ថា វាជាសេចក្តីសម្រេចដែលមានលក្ខណៈដាច់ខាតផង។ ក្នុងនាមជាអ្នកអាន អ្នកត្រូវជួយជាមតិរិះគន់។ មានពេលខ្លះយុត្តិសាស្ត្ររបស់តុលាការកំពូលក៏មានការកែប្រែតាមរយៈការរិះគន់នានា។ ចំណែកឯនៅក្នុងទ្រឹស្តីវិញ គេកម្រនឹងឃើញថាមានការបកស្រាយដែលមានលក្ខណៈដូចគ្នាទាំងស្រុងណាស់។

៤. មើលឲ្យឃើញអំពីចំនុចសំខាន់

ដើម្បីឆ្លើយនឹងសំណួរករណីសិក្សាឬបញ្ហាជួបប្រទះរឿងក្តីជាក់ស្តែង អ្នកត្រូវតែស្វែងរកឲ្យឃើញ តើអង្គហេតុចាំបាច់ណាដែលត្រូវយកមកពិចារណាតាមទ្រឹស្តីច្បាប់? សមត្ថភាពស្វែងរកនូវចំនុចសំខាន់លក្ខណៈគតិយុត្តពីព័ត៌មានដែលច្រើនលើសលប់ ក៏អាចហៅថា Legal Mind ដែរ។

១-៤ ចំណុចប្រសព្វនៃមុខវិជ្ជាដែលប្រហាក់ប្រហែលគ្នា

១. សមត្ថភាពរបស់អ្នកច្បាប់

សមត្ថភាពមួយដែលគេរំពឹងពីអ្នកច្បាប់ គឺជាសមត្ថភាពវិនិច្ឆ័យ ដែលវាជាសមត្ថភាពធ្វើឲ្យភាគីជំទាស់និងមនុស្សជុំវិញអាចយល់ស្របតាមគំនិតរបស់អ្នក។ សំនួរសួរថា តើយើងនឹងគាំទ្រគោលជំហរមួយត្រឹមកម្រិតណា ប្រសិនបើមានភាពចម្រុងចម្រះគ្នារវាង "ផលប្រយោជន៍"និង "ផលប្រយោជន៍នោះជាហេតុនៃបញ្ហា"?

ដើម្បីរកឲ្យឃើញនូវឫសគល់នៃភាពចម្រូងចម្រះឲ្យបានត្រឹមត្រូវ ការសិក្សាច្បាប់តែមួយមុខមិនគ្រប់គ្រាន់ទេ។ ដោយសារតែផលប្រយោជន៍ដែលត្រូវពិចារណានោះ គឺមានបាតុភូតសង្គមផ្សេងៗនៅពីក្រោយ។

ហេតុនេះ មុខវិជ្ជាសង្គមផ្សេងៗដូចជា នយោបាយ ចិត្តវិជ្ជា សង្គមវិជ្ជា ជាពិសេសមុខវិជ្ជាសេដ្ឋកិច្ច គឺមានសារៈសំខាន់ណាស់សម្រាប់រៃកញ្ជែកឲ្យបានស៊ីជម្រៅនៅក្នុងការវិភាគច្បាប់។ ជាពិសេសច្បាប់ពាណិជ្ជកម្ម ច្បាប់សេដ្ឋកិច្ច និងមួយផ្នែកនៃច្បាប់រដ្ឋប្បវេណីជាអាទិ៍អាចជាកម្មវត្ថុនៃបាតុភូតសេដ្ឋកិច្ចដែរ។ យ៉ាងហោចណាស់ក៏ច្បាប់ទាំងនោះ មានទំនាក់ទំនងបន្តិចបន្តួចទៅនឹងបាតុភូតសេដ្ឋកិច្ចដែរ។

២. ភាពសមស្របនៃប្រព័ន្ធច្បាប់កំពុងដំណើរការ

ឧទាហរណ៍ ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ ការបំពុលបរិស្ថាន ឬក៏ការធ្វើឲ្យខូចខាតដល់ទ្រព្យសម្បត្តិ ឬរាងកាយរបស់អ្នកដទៃដោយសារតែការធ្វេសប្រហែសរបស់ខ្លួន ច្បាប់បានកំណត់ថា ជនបង្កត្រូវតែសងសំណងខូចខាតដល់ជនរងគ្រោះ(អំពើអនីត្យានុកូលតាមក្រមរដ្ឋប្បវេណី)។ មាត្រានៃអំពើអនីត្យានុកូលនេះមានគោលគំនិត២ គឺ "ចាំបាច់ជួយសង្គ្រោះដល់ជនរងគ្រោះ" និង "ការរក្សានូវភាពត្រឹមត្រូវនិងយុត្តិធម៌នៃការទទួលខុសត្រូវលើការខូចខាតរវាងជនរងគ្រោះនិងជនបង្ក"។

ប៉ុន្តែ យើងអាចបកស្រាយបានថា មូលហេតុដែលបង្កើតនូវប្រព័ន្ធសងសំណងខូចខាតក្នុងករណីមានកំហុសនោះ ដោយសារតែជនបង្កត្រូវតែមានការប្រុងប្រយ័ត្នចំពោះអ្នកដទៃ។ ប៉ុន្តែ

ប្រសិនបើប្រព័ន្ធធានារ៉ាប់រងរឹកសាយ ទោះបីជាជនបង្កត្រូវទទួលការជំនុំជំរះខាងផ្នែកព្រហ្មទណ្ឌ (ពិន័យជាប្រាក់ឬពន្ធនាគារ) ឬ ផ្នែករដ្ឋបាល (ផ្អាកឬលុបចោលអាជ្ញាបណ្ណ) ក៏ដោយ ប្រសិនបើការទទួលខុសត្រូវស្ថិតត្រឹមទំហំនៃប្រាក់ធានារ៉ាប់រងទេ នោះវាមិនធ្វើឲ្យជនបង្កត្រូវចេញលុយពីហោប៉ៅរបស់ខ្លួនទេ។ ករណីគ្រោះថ្នាក់ចរាចរណ៍ ជាគោលការណ៍ថ្លៃសេវាធានារ៉ាប់រងត្រូវតម្លើងចាប់ពីឆ្នាំបន្ទាប់ទៅ បន្ទាប់ពីមានគ្រោះថ្នាក់។ តាមរយៈការតម្លើងថ្លៃនេះ ជនបង្កនោះនឹងភ្ញាក់រលឹកគួរចៀសវាងគ្រោះថ្នាក់ចរាចរណ៍។

១-៥ អាត្រាច្បាប់ជាចំនុចចាប់ផ្តើម

១. ច្បាប់ជា "បច្ចេកទេសនៃការពន្យល់ឲ្យគេយល់ស្របតាម"

អ្វីដែលគួរឲ្យភ្ញាក់ផ្អើលអំពីសិក្សាច្បាប់នោះ គឺមានទ្រឹស្តីនិងយុត្តិសាស្ត្រច្រើន។ ដោយសារតែអ្នកស្រាវជ្រាវម្នាក់ៗមានការយល់ឃើញខុសៗគ្នា ទើបធ្វើឲ្យមានការសន្និដ្ឋានផ្សេងៗជាច្រើន។ យើងមិនអាចសម្រេចថា "ខុស" ឬ "ត្រូវ" តាមរយៈសេចក្តីសន្និដ្ឋានតែមួយមុខនោះទេ។

ការសិក្សាច្បាប់ គឺជាការសិក្សានូវបច្ចេកទេសបញ្ចុះបញ្ចូលដែលមានចំនុចសំខាន់២ គឺ "ភាពត្រឹមត្រូវនៃសេចក្តីសន្និដ្ឋាន" និង "មូលហេតុដែលឆ្ពោះទៅសេចក្តីសន្និដ្ឋាន"។ ប្រសិនបើខ្វះនូវចំនុចណាមួយ នោះវាពិបាកពន្យល់ឲ្យភាគីម្ខាងទៀតយល់ស្របណាស់។

២. ភាពត្រឹមត្រូវនៃសេចក្តីសន្និដ្ឋាននិងមាត្រាច្បាប់

ក្នុងសង្គមមានរស់នៅមនុស្សច្រើន យើងពិបាកជៀសផុតពីការប៉ះទង្គិចផលប្រយោជន៍ណាស់។ សេចក្តីសន្និដ្ឋាន ក៏ត្រូវផ្អែកលើចិត្តសាស្ត្រមនុស្សនិងសង្គមដែរ។ តួនាទីចម្បងនៃច្បាប់គឺធ្វើការសម្របសម្រួលបញ្ហាទាំងនោះ។ សំខាន់អ្នកសិក្សាត្រូវចាប់ឲ្យបានថា តើមានផលប្រយោជន៍បែបណាប៉ះទង្គិចជាមួយនឹងផលប្រយោជន៍បែបណា?

ឧទាហរណ៍ក្នុងនីតិក្រុមហ៊ុន ការប្រឈមគ្នារវាង "ផលប្រយោជន៍ក្រុមហ៊ុន" និង "សុវត្ថិភាពនៃការធ្វើពាណិជ្ជកម្ម" កើតមានឡើងញឹកញាប់។ ដោយឡែក វាអាចមានករណីដែល "ផលប្រយោជន៍

ក្រុមហ៊ុន" និង "សុវត្ថិភាពនៃការធ្វើពាណិជ្ជកម្ម" នៅស្របគ្នាដែរ។ ដោយសារតែក្រុមហ៊ុនបង្កើនផលចំណេញតាមរយៈការរកស៊ីជាមួយដៃគូជំនួញដទៃទៀត ដូច្នេះ"សុវត្ថិភាពនៃកិច្ចការជំនួញ" គឺចាំបាច់ខ្លាំងណាស់សម្រាប់ការធ្វើជំនួញក្នុងទំហំធំនិងរហ័ស។

យើងត្រូវវិភាគថា តើច្បាប់មានតម្លៃដែលគួរពិចារណាបែបណា? ឧទាហរណ៍ "ការការពារអ្នកដែលមានសិទ្ធិពិតប្រាកដ" និង "សុវត្ថិភាពនៃកិច្ចការជំនួញ"។ តើគួរតែចាប់យកតុល្យភាពនៅត្រង់ចំនុចណា? សន្និដ្ឋានយ៉ាងណាទើបអាចធ្វើឲ្យវាក្លាយជាសេចក្តីសន្និដ្ឋានដែលមានឥទ្ធិពល?

៣. "ផ្លូវទៅកាន់សេចក្តីសន្និដ្ឋាន" និងមាត្រាច្បាប់

ប្រសិនបើគំនិតមួយ "ត្រឹមត្រូវ" មានន័យថា "ផ្លូវទៅកាន់សេចក្តីសន្និដ្ឋាន" របស់គំនិតនោះក៏ត្រឹមត្រូវដែរ។ ជាគោលការណ៍ មាត្រាដែលមានចែងនៅក្នុងច្បាប់គឺជាចំនុចនៃការចាប់ផ្តើម។ រកមាត្រាឲ្យបានត្រឹមត្រូវ នោះផ្លូវទៅកាន់សេចក្តីសន្និដ្ឋាននឹងមានភាព "ត្រឹមត្រូវ" ភាគច្រើន។ ដោយឡែក ប្រសិនបើរកឃើញមាត្រាហើយ តែអ្នកបែរជាគ្មានមូលដ្ឋានគ្រប់គ្រាន់មិនអាចទាញទៅរកសេចក្តីសន្និដ្ឋានសមស្របទេនោះ ក៏មិនឥតប្រយោជន៍ដែរ។

ជារួម យើងត្រូវយកមាត្រាច្បាប់ធ្វើជាណុចណុចចាប់ផ្តើម ហើយយើងក៏ត្រូវដឹងពីការបកស្រាយមាត្រាដែរ។ ដោយឡែក ក្នុងករណីដែលអ្នកមិនអាចទាញសេចក្តីសន្និដ្ឋានឲ្យបានសមស្របឬក៏គ្មានមាត្រាណាចែងដោយផ្ទាល់ទេនោះ តើអ្នកគួរតែដោះស្រាយបែបណា? ការបង្ហាញសមត្ថភាពអ្នកចេះច្បាប់ គឺនៅត្រង់នេះហើយ។

វិធីសាស្ត្រសម្រាប់ដោះស្រាយនោះមានដូចជា ការបកស្រាយពង្រីក ការបកស្រាយបង្រួម ការបកស្រាយប្រដូច និងការបកស្រាយបញ្ច្រាសជាដើម។ វិធីសាស្ត្រទាំងអស់នោះ គឺអាចប្រើប្រាស់បានដោយផ្អែកតាមគោលបំណងនិងកម្មវត្ថុនៃការតាក់តែងមាត្រានោះ។

៤. អ្វីទៅជាការបកស្រាយបង្រួម?

ការបកស្រាយបង្រួម គឺជាការបកស្រាយដែលបង្រួមនូវិសាលភាពនៃអត្ថន័យរបស់វាក្យសព្ទ ឬ ពាក្យពេចន៍ដែលមានចែងនៅក្នុងមាត្រាតាមរយៈចំណេះដឹងទូទៅ។ ឧទាហរណ៍ មានបម្រាមមួយ

"ហាមនាំសត្វឆ្កែចូលក្នុងហាង" ក៏ដោយ ក៏ប៉ុន្តែគេអាចបកស្រាយបានថា អនុញ្ញាតឲ្យនាំសត្វឆ្កែដែលអាចនាំផ្លូវជនពិការចូលហាងបានផងដែរ។ ករណីមិនអាចប្រើការបកស្រាយបង្រួមបានទេ គេនឹងប្រើប្រាស់គោលការណ៍សច្ចភាព គោលការណ៍នៃភាពសុចរិតនិងភាពស្មោះត្រង់តាមក្រមរដ្ឋប្បវេណី។ ដូចគ្នាផងដែរចំពោះការអនុវត្តសិទ្ធិឬករណីយកិច្ចនៃកិច្ចសន្យា ត្រូវតែធ្វើឡើងដោយភាពស្មោះត្រង់ដោយមិនក្បត់ពីការរំពឹងទុកឬភាពជឿជាក់ពីដៃគូឡើយ។ ឬមួយទៀត គេនឹងប្រើប្រាស់នូវគោលការណ៍នៃការប្រើប្រាស់សិទ្ធិដោយបំពានជាដើម។

ករណីគ្មានមាត្រាបញ្ញត្តិផ្ទាល់ទេ អ្នកនៅមានលទ្ធភាពបកស្រាយពង្រីក បកស្រាយប្រដូច ឬបកស្រាយបញ្ច្រាសបាន។ តើយើងគួរប្រើប្រាស់វិធីបកស្រាយមួយណានោះ គឺអាស្រ័យលើភាពសមស្របនៃសេចក្តីសន្និដ្ឋាន។ តើឈរលើវិធីបកស្រាយណាមួយ ទើបក្លាយជាការបកស្រាយដែលសមស្របតាមស្មារតីក្រមរដ្ឋប្បវេណី? តើគួរសង្កត់ធ្ងន់លើការថ្លឹងថ្លែងផលប្រយោជន៍នានាដែលកំពុងប្រឈមជាក់គ្នាដោយរបៀបណា?

៥. អ្វីទៅជាការបកស្រាយពង្រីក?

ការបកស្រាយពង្រីក គឺជាពិចារណាពង្រីកផ្អែកតាមចំណេះដឹងទូទៅលើវិសាលភាពនៃអត្ថន័យពាក្យពេចន៍/វាក្យសព្ទនៃមាត្រា។

៦. អ្វីទៅជាការអនុវត្តប្រដូច?

ការអនុវត្តប្រដូចត្រូវបានប្រើប្រាស់ពេលដែលមិនអាចធ្វើការបកស្រាយពង្រីកបាននិងក្នុងករណីដែលមិនមានមាត្រាណាចែងច្បាស់ពីវា។

៧. អ្វីទៅជាការបកស្រាយបញ្ច្រាស?

ការបកស្រាយបញ្ច្រាស គឺជាការបកស្រាយអានុភាពបញ្ច្រាសពីខ្លឹមសារនៃមាត្រាណាមួយដែលមានចែងច្បាស់លាស់។ ឧទាហរណ៍ ការហាមឃាត់នរណាម្នាក់ក្នុងការធ្វើសកម្មភាពណាមួយឬតម្រូវឲ្យធ្វើកាតព្វកិច្ចណាមួយចំពោះករណីជាក់លាក់នៅក្នុងមាត្រាណាមួយ នាំឲ្យក្រៅពីករណីដែលច្បាប់បានកំណត់ឬក្រៅពីជនដែលបានកំណត់ច្បាប់មិនបានហាមឃាត់ឬតម្រូវកាតព្វកិច្ចឡើយ ។

ឧទាហរណ៍ មានបម្រាមថា "ហាមនាំសត្វឆ្កែចូលក្នុងហាង" គេអាចយល់បានថាគេអាចនាំសត្វឆ្មា ឬសត្វចាបចូលបាន។

ជំពូកទី២

សិក្ខាបន[1]ច្បាប់

[1] ភាសាអង់គ្លេស Lecture។

២-១. គុណសម្បត្តិនៃស្តាប់សិក្ខាប័នច្បាប់

នៅសាកលវិទ្យាល័យ អ្នកច្បាស់ជាស្គាល់បរិយាកាសសិក្សា។ បណ្ណាល័យមានសៀវភៅជាច្រើន រហូតថ្នាក់អ្នកមិនដឹងថាត្រូវអានអ្វីមុន។ ក៏ប៉ុន្តែ បន្ទាប់ពីបានស្តាប់សិក្ខាប័នច្បាប់ យើងនឹងដឹងបានថាវាជារឿងដដែលៗដោយគ្រាន់តែមានការបន្ថែមគ្រឿងធ្វើឲ្យអ្នកស្តាប់ងាយយល់តាមមុខជំនាញមួយៗតែប៉ុណ្ណោះ។ ឧទាហរណ៍ នៅក្នុងនីតិរដ្ឋប្បវេណីមាន "ការការពារលើសិទ្ធិបុគ្គល" និង "សុវត្ថិភាពជំនួញ" ដែលបង្កប់នៅតាមចំនុចនានា។

មានរៀមច្បងនិងមិត្តភក្តិប្រាប់ថា «វាខាតពេលខ្លាំងណាស់ក្នុងការស្តាប់សិក្ខាប័នបែបនេះ» ។ មិត្តភក្តិជាច្រើនបានគេចម៉ោងរៀនរបស់សាកលវិទ្យាល័យ។ ក៏ប៉ុន្តែ រៀនអ្វីក៏ដោយបើយើងរៀនសូត្រពីមនុស្សពូកែ យើងនឹងទទួលបានអាថ៌កំបាំងដើម្បីធ្វើឲ្យខ្លួនឯងរីកចម្រើនបានយ៉ាងលឿន។ ការសិក្សាច្បាប់ក៏ដូច្នេះដែរ ការរៀនសូត្រពីសិក្ខាប័នច្បាប់ឬក៏ឲ្យរៀមច្បងជួយបង្រៀនគឺអាចសន្សំពេលវេលាច្រើនជាងការអានសៀវភៅដោយខ្លួនឯង។

នៅក្នុងការសិក្សាច្បាប់ ត្រូវចេះក្តាប់ជារូបភាពឬយល់ជាគោលការណ៍រួម។ សម្រាប់អ្នកសិក្សាជំហានដំបូងមួយចំនួនអាចមានអារម្មណ៍ថា វាលំបាកណាស់នៅពេលអានសៀវភៅពុម្ពធំ។ អ្នកអាចវង្វេងក្នុងការយល់ដឹងនូវចំនុចនីមួយៗដែលមានក្នុងរូបភាពជារួម។ ហេតុនេះ អ្នកត្រូវចូលស្តាប់សិក្ខាប័នរបស់សាស្ត្រាចារ្យដើម្បីទទួលបានការពន្យល់ស្តីពីចំនុចតូចៗនិងទំនាក់ទំនងរបស់វា។

ម្យ៉ាងទៀត ពេលស្តាប់ការបង្រៀនរបស់គ្រូ អ្នកនឹងយល់ថាពីចំនុចសំខាន់មួយៗមាននៅទីណា ដូច្នេះអ្នកនឹងមិនចាំបាច់ចំណាយកម្លាំងហត់ដូចអានសៀវភៅតែម្នាក់ឯងនោះទេ។ ហើយអ្វីដែលគ្រូចំណាយពេលពន្យល់លម្អិតច្រើននៅក្នុងម៉ោងបង្រៀន គឺភាគច្រើននឹងជាសំណួរប្រលងឆមាស។ បើសិនវាជាផ្នែកសំខាន់ពិតប្រាកដនៃមេរៀនជាទូទៅនោះ គ្រូណាក៏លើកឡើងដូចៗគ្នាដែរ។

កាលពីអតីតកាល ខ្ញុំធ្លាប់ជួយសិស្សប្អូនដែលរៀនម៉ោងគួរតូចក្នុងការប្រលងវិជ្ជាជីវៈច្បាប់។ សិស្សប្អូនទាំងនោះពិតជាពូកែៗណាស់ តែខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដឹងថា គាត់មិនចេះពីរបៀបអានពាក្យបច្ចេកទេសច្បាប់។ ឧទាហរណ៍ពាក្យ វិការៈ តតិយជនជាដើម គាត់មិនចេះអានទេ។ ឃ្លាដែល

មានលក្ខណៈបច្ចេកទេសច្បាប់គឺមានច្រើន ហើយជាភាសាដែលគេមិនសូវប្រើទូលំទូលាយនៅក្នុងសម័យបច្ចុប្បន្នទេ ហេតុនេះបើអ្នកចូលស្តាប់បទបង្ហាញឬការបង្រៀន នោះអ្នកនឹងដឹងអំពីរបៀបអាន។ បើសិនជាអ្នកមិនចេះរបៀបអានទេ អ្នកនឹងទទួលបានលទ្ធផលមិនល្អនៅពេលប្រលងចូលក្របខណ្ឌឬប្រលងចូលវិជ្ជាជីវៈវគ្គសំភាសន៍ផ្ទាល់មាត់ទេ។ ម្យ៉ាងទៀត ពេលអ្នកចេញធ្វើការនៅក្នុងសង្គមប្រហែលជាមនុស្សជុំវិញនឹងអាចសង្ស័យចំពោះសមត្ថភាពចំណេះដឹងច្បាប់របស់អ្នកផង។

ហេតុនេះ ការចូលរួមស្តាប់ការបង្រៀនឬបទបង្ហាញរបស់គ្រូល្អៗ គឺមានគុណប្រយោជន៍សំខាន់ណាស់។ ពាក្យច្បាប់មួយចំនួនមិនប្រើក្នុងភាសានិយាយប្រចាំថ្ងៃនោះទេ។ ដូច្នេះហើយ គ្រូបកស្រាយពាក្យពេចន៍ទាំងនោះទៅជាភាសាធម្មតាដើម្បីឲ្យងាយស្រួលយល់ដែលជាវិធីធ្វើឲ្យយើងអាចពិចារណាដល់ទិដ្ឋភាពជាក់ស្តែងបាន។ សៀវភៅខ្លះគេលើកយកតែគំនិតមួយចំនួនយកមកបង្ហាញដោយមិនបង្ហាញអំពីនិន្នាការនៃទ្រឹស្តីច្បាប់ផ្សេងទៀតឡើយ។ ហេតុនេះ បើអ្នកចង់ដឹងអំពីនិន្នាការនៃទ្រឹស្តីទាំងនោះ អ្នកចាំបាច់ត្រូវអានសៀវភៅឲ្យបានច្រើនក្បាល។ វាមិនមែនជាការងាយស្រួលឡើយក្នុងការយល់ពីទំនាក់ទំនងនៃទ្រឹស្តីទាំងនោះបានតាមរយៈសៀវភៅមេរៀន។ គ្រូនឹងធ្វើពន្យល់ពីរឿងរ៉ាវទាំងនោះនៅក្នុងថ្នាក់ និស្សិតនឹងអានសន្សំសំចៃពេលវេលាច្រើនបាន។

២-២. របៀបជ្រើសរើសមុខវិជ្ជាច្បាប់

ជាដំបូងនិស្សិតត្រូវរៀនមុខវិជ្ជាសេចក្តីផ្តើមនីតិសិន ដើម្បីក្តាប់ឲ្យបានអំពីមូលដ្ឋានជារួម។ នៅក្នុងមុខវិជ្ជាសេចក្តីផ្តើមនីតិនោះ ក៏បង្ហាញឲ្យនិស្សិតបានឃើញអំពីមុខវិជ្ជាច្បាប់ផ្សេងៗទៀតផងដែរ។

មុខវិជ្ជាដែលមានបង្រៀននៅក្នុងកម្មវិធីប្រព័ន្ធសិក្សាផ្នែកនីតិសាស្ត្រ មានដូចជា៖ នីតិសាធារណៈ នីតិឯកជន នីតិព្រហ្មទណ្ឌ នីតិការងារ នីតិរបបសន្តិសុខសង្គម នីតិអន្តរជាតិ និង នីតិជាមូលដ្ឋានផ្សេងទៀត។ មុខវិជ្ជានីមួយៗ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និតរវាងមុខវិជ្ជាគ្នាទៅវិញទៅមក។

ដំបូង ចំពោះមុខវិជ្ជានីតិសាធារណៈ រួមមានមុខវិជ្ជា នីតិរដ្ឋធម្មនុញ្ញ និងនីតិរដ្ឋបាល។ មានការបកស្រាយបានលើកឡើងថា ការសិក្សានីតិអន្តរជាតិក៏ទាក់ទងនឹងមុខវិជ្ជានៃនីតិសាធារណៈនេះដែរ។

រីឯ ដើម្បីអាចសិក្សានីតិរដ្ឋបាលបាន អ្នកត្រូវមានចំណេះដឹងមូលដ្ឋាននៃនីតិរដ្ឋធម្មនុញ្ញ ហេតុនេះហើយ ទើបសាកលវិទ្យាល័យភាគច្រើនតម្រូវឲ្យនិស្សិតសិក្សាមុខវិជ្ជានីតិរដ្ឋធម្មនុញ្ញនៅក្នុងឆ្នាំទី១ និងសិក្សាអំពីនីតិរដ្ឋបាលនៅឆ្នាំបន្តបន្ទាប់។ ថ្មីៗនេះ មានមុខវិជ្ជានីតិពន្ធដារផងដែរ ហើយនេះក៏ជាផ្នែកមួយនៃនីតិរដ្ឋបាល។ ជាពិសេសនៅក្នុងនីតិពន្ធដារនេះក៏មានទំនាក់ទំនងជាមួយទៅនឹងពន្ធលើសន្តតិកម្មផងដែរ អ្នកត្រូវមានចំណេះដឹងអំពីនីតិគ្រួសារនិងនីតិសន្តតិកម្ម ដែលជាផ្នែកមួយនៃនីតិរដ្ឋប្បវេណីផងដែរ។ ម្យ៉ាងទៀតថ្មីៗនេះ គេក៏បានផ្តោតសំខាន់យ៉ាងខ្លាំងទៅលើនីតិបរិស្ថានដែលមានទំនាក់ទំនងនឹងនីតិរដ្ឋបាលផងនិងនីតិរដ្ឋប្បវេណីផង។ ហេតុនេះ បើអ្នកជ្រើសរើសនូវសិក្សាជំនាញនីតិរដ្ឋបាល ភាគច្រើនអ្នកនឹងទទួលបានប្រសិទ្ធភាពខ្ពស់ពីការសិក្សា។

ចំពោះ នីតិឯកជនវិញ មាននីតិរដ្ឋប្បវេណីដែលស្នូលដ៏សំខាន់។ សាកលវិទ្យាល័យ បានបែងចែងនូវជំនាញផ្នែករដ្ឋប្បវេណីជាមុខវិជ្ជាផ្សេងៗទៀតរួមមាន គោលការណ៍ទូទៅនៃក្រមរដ្ឋប្បវេណី នីតិប្រាតិភោគ នីតិស្តីពីសិទ្ធិប្រក្សត្យ នីតិកាតព្វកិច្ច នីតិស្តីពីអំពើអនីត្យានុកូល នីតិគ្រួសារ នីតិសន្តតិកម្ម ជាដើម។ ជាងនេះទៅទៀត សាកលវិទ្យាល័យខ្លះក៏មុខវិជ្ជានីតិអចលនទ្រព្យផងដែរ។ មិនតែប៉ុណ្ណោះ ថ្មីៗនេះ ក៏មាននីតិធនាគារ ក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរ។

ចំណែកឯនីតិពាណិជ្ជកម្មនិងនីតិក្រុមហ៊ុនវិញ ជាមុខវិជ្ជាយ៉ាងសំខាន់នៅក្នុងនីតិឯកជន។ សាកលវិទ្យាល័យខ្លះក៏បានចែកជំនាញទាំងនេះជាមុខវិជ្ជានីតិពាណិជ្ជកម្ម នីតិពាណិជ្ជកម្មសមុទ្រ នីតិដឹកជញ្ជូន នីតិធានារ៉ាប់រង នីតិមូលប័ត្រ ជាដើម។ រីឯ នីតិជំនួញអន្តរជាតិវិញ ជាមុខវិជ្ជាយ៉ាងសំខាន់នៅក្នុងនីតិឯកជនដែរ។ ដើម្បីអាចយល់មេរៀននៃនីតិពាណិជ្ជកម្មឬនីតិក្រុមហ៊ុនបាន អ្នកត្រូវយល់ដឹងពី នីតិរដ្ឋប្បវេណី ជាពិសេសគឺគោលការណ៍ទូទៅនៃក្រមរដ្ឋប្បវេណី នីតិស្តីពីសិទ្ធិប្រក្សត្យ នីតិកាតព្វកិច្ច និងនីតិប្រាតិភោគជាចាំបាច់។ ជាទូទៅអ្នកគួរតែសិក្សាពីនីតិរដ្ឋប្បវេណីជាមុន មុននឹងចាប់ផ្តើមសិក្សានីតិពាណិជ្ជកម្ម។ ហើយដើម្បីអាចស្វែងយល់ពីការសិក្សានីតិពាណិជ្ជកម្មនេះដែរ គឺទាមទារឲ្យអ្នកមានការយល់ដឹងពីនីតិពន្ធដារនិងនីតិសេដ្ឋកិច្ចផងដែរ ពីព្រោះថាតាមការអនុវត្តជាក់ស្តែងនៅក្នុងសហគ្រាសគឺកំពុងតែប្រើប្រាស់ច្បាប់ទាំងនេះ។ ជាងនេះទៅទៀត មុខវិជ្ជានីតិសេដ្ឋកិច្ច ក៏ជាជ្រុងមួយនៃនីតិរដ្ឋបាល

ផងដែរ។ ម្យ៉ាងទៀតមុខនីតិពាណិជ្ជកម្មនិងនីតិក្រុមហ៊ុនក៏មានទំនាក់ទំនងខ្លាំងជាមួយនឹងនីតិកម្មសិទ្ធិបញ្ញាដែរ។

រីឯ មុខវិជ្ជានីតិរដ្ឋប្បវេណីវិញ ក៏ជាមុខវិជ្ជាមួយដ៏មានសារៈសំខាន់ចំពោះនីតិឯកជន រួមមាននីតិវិធីបណ្តឹងរដ្ឋប្បវេណី នីតិស្តីពីការរក្សាការពារ នីតិស្តីពីការអនុវត្តដោយបង្ខំ និងនីតិស្តីពីការចាត់ចែងការក្សេីយធនជាដើម។ នៅក្នុងចំណោមនីតិដែលបានលើកឡើងនេះ អ្នកត្រូវមានការយល់ដឹងពីមុខវិជ្ជាមានដែលនៅក្នុងនីតិរដ្ឋប្បវេណី ជាពិសេស នីតិស្តីពីសិទ្ធិប្រក្សត្យ នីតិកាតព្វកិច្ច និងនីតិប្រាតិភោគជាមុនសិន។ ហេតុនេះ អ្នកត្រូវសិក្សាទាំងនីតិរដ្ឋប្បវេណីនិងនីតិវិធីរដ្ឋប្បវេណី ទើបនាំឲ្យការសិក្សា មានប្រសិទ្ធិភាពនឹងអាចផ្សាភ្ជាប់ការយល់ដឹងជាមួយនឹងការអនុវត្តជាក់ស្តែងបាន។

បន្ថែមពីអ្វីដែលបានលើកឡើងខាងលើ គេចាប់អារម្មណ៍ថា នីតិកម្មសិទ្ធិបញ្ញាកំពុងតែមានរីកលូតលាស់នាពេលថ្មីៗនេះ។ នៅក្នុងនីតិកម្មសិទ្ធិបញ្ញា រួមមានមុខវិជ្ជាដូចជា នីតិស្តីពីម៉ាក នីតិគ្រាប់ពូជ នីតិស្តីពីការប្រកួតប្រជែងមិនស្មោះត្រង់ ជាដើម ។ ដើម្បីអាចយល់ដឹងអំពីនីតិអស់ទាំងបាននេះ អ្នកត្រូវមានការយល់ដឹងពីនីតិរដ្ឋបាលនិងនីតិរដ្ឋប្បវេណី។

ចំណែកឯ មុខវិជ្ជាជំនាញផ្នែកព្រហ្មទណ្ឌវិញ រួមមានមុខវិជ្ជា នីតិព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ នីតិស្តីពីគោលការណ៍ព្រហ្មទណ្ឌ នីតិព្រហ្មទណ្ឌវិទ្យា នីតិអនីតិជន នីតិវេជ្ជសាស្ត្រព្រហ្មទណ្ឌ ក៏មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនីតិនេះផងដែរ។ ការសិក្សានីតិព្រហ្មទណ្ឌ អ្នកត្រូវមានយល់ដឹងឲ្យបានគ្រប់គ្រាន់ស្តីពីនីតិរដ្ឋធម្មនុញ្ញ ជាពិសេសនីតិសិទ្ធិមនុស្ស។ នៅពេលដែលពិភាក្សាអំពីនីតិវិធីព្រហ្មទណ្ឌវិញ គោលការណ៍ដែលមាននៅក្នុងរដ្ឋធម្មនុញ្ញនឹងត្រូវលើកមកវែកញែកផងដែរ។ ចំណែក មុខវិជ្ជាគោលនយោបាយព្រហ្មទណ្ឌវិញ មិនមានភាពជិតស្និតខ្លាំងទៅនឹងមុខវិជ្ជាច្បាប់ប៉ុន្មានទេ។ ប៉ុន្តែ ជាក់ស្តែងច្បាប់ស្តីពីពន្ធធនាគារ ច្បាប់ស្តីពីអនីតិជន ច្បាប់ស្តីពីក្រុមប្រឹក្សាអនីតិជន ច្បាប់ស្តីពីការការពារតាមប្រព័ន្ធយុត្តិធម៌ ច្បាប់ស្តីពីការការពារក្នុងការចូលរួមក្នុងសង្គមឡើងវិញ ត្រូវបានចាត់ចូលក្នុងមុខវិជ្ជាគោលនយោបាយព្រហ្មទណ្ឌផងដែរ។ ដើម្បីអាចរៀនមុខវិជ្ជាគោលនយោបាយព្រហ្មទណ្ឌនេះបាន អ្នកត្រូវចេះច្បាស់អំពីគោលការណ៍ទូទៅនៃក្រមព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌ។

ចំណែកឯ នីតិការងារនិងនីតិរបបសន្តិសុខសង្គមវិញ នីតិការងាររួមមាន ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីស្តង់ដារការងារជាដើម និង នីតិរបបសន្តិសុខសង្គមរួមមាន ច្បាប់ស្តីពីធានារ៉ាប់រងសង្គម ច្បាប់ស្តីពីសុខមាលភាពសង្គម និងច្បាប់ស្តីពីជំនួយផ្នែកសាធារណៈជាដើម។ ក្នុងចំណោមខាងលើនេះ មុខវិជ្ជាមួយណាក៏ដោយ ចាំបាច់ចំណេះដឹងអំពីនីតិរដ្ឋធម្មនុញ្ញនិងនីតិរដ្ឋបាលជាមុនសិនដែរ។

រីឯមុខវិជ្ជានីតិអន្តរជាតិវិញ រួមមាននីតិអន្តរជាតិឯកជន និង នីតិអន្តរជាតិសាធារណៈ។ មុខវិជ្ជា២នេះ ហាក់បីដូចជាមុនសូវមានទំនាក់ទំនងនឹងគ្នាប៉ុន្មានទេ។ នីតិអន្តរជាតិសាធារណៈ រួមមាន នីតិព្រហ្មទណ្ឌអន្តរជាតិ នីតិសេដ្ឋកិច្ចអន្តរជាតិ និងនីតិសិទ្ធិមនុស្សអន្តរជាតិ។ មុខវិជ្ជាទាំងអស់នេះពិតជាមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងនីតិរដ្ឋធម្មនុញ្ញ នីតិព្រហ្មទណ្ឌ នីតិរដ្ឋបាល និងនីតិសេដ្ឋកិច្ច។ ទាល់តែអ្នកសិក្សាទាំងអស់ទើបការសិក្សានឹងមានប្រសិទ្ធិភាព។ ចំណែក នីតិអន្តរជាតិឯកជនវិញ នឹងសិក្សាពីចំណោទថា តើតុលាការនៃប្រទេសណាជាតុលាការមានសមត្ថកិច្ច? តើយកច្បាប់របស់ប្រទេសណាមកអនុវត្ត? ជាដើម។ ហេតុនេះមុខវិជ្ជានេះមានទំនាក់ទំនងខ្លាំងជាមួយនឹង នីតិវិធីរដ្ឋប្បវេណី។

នៅក្នុងមុខវិជ្ជាសេចក្តីផ្តើមនីតិជាមូលដ្ឋានវិញ រួមមាន នីតិសង្គមវិជ្ជា នីតិទស្សនៈវិជ្ជាច្បាប់ ប្រវត្តិគំនិតច្បាប់ ប្រវត្តិប្រព័ន្ធច្បាប់ ច្បាប់រ៉ូម៉ាំង ច្បាប់បរទេសជាដើម។

អ្វីដែលបានលើកឡើងនូវខាងលើទាំងអស់នេះ ទាមទារឲ្យអ្នកសិក្សាឲ្យបានស៊ីជម្រៅទៅលើច្បាប់សារជាតុ និងយល់អំពីចំនុចសំខាន់ៗ។ ឧទាហរណ៍ ច្បាប់ដែលសំខាន់ៗនៅក្នុងប្រទេសជប៉ុន រួមមាន នីតិរដ្ឋធម្មនុញ្ញ ច្បាប់រដ្ឋបាល នីតិរដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម ច្បាប់ក្រុមហ៊ុន នីតិវិធីព្រហ្មទណ្ឌ។ គួរបញ្ជាក់ផងដែរថា ច្បាប់ទាំងនេះបានទទួលឥទ្ធិពលពីច្បាប់បរទេសស្ទើរតែទាំងស្រុង ដូចជា ច្បាប់របស់ប្រទេសអង់គ្លេស ប្រទេសអាល្លឺម៉ង់ ប្រទេសបារាំង និង ច្បាប់នៃប្រទេសរូម៉ាំងជាដើម។ ហេតុនេះ អ្នកត្រូវមានចំណេះដឹងស្តីពីច្បាប់អស់ទាំងនោះផងដែរ។ មិនមែនគ្រាន់តែមើលថា តើច្បាប់នាបច្ចុប្បន្នដើរដល់ណាតែប៉ុណ្ណឹងនោះទេ អ្នកគប្បីត្រូវស្វែងយល់ថាតើច្បាប់ត្រូវបង្កើតឡើងយ៉ាងដូចម្តេច? ហើយច្បាប់នោះត្រូវមានអត្ថន័យយ៉ាងដូចម្តេចផងដែរ។

ពោលគឺ អ្នកត្រូវមានចំណេះដឹងពីទស្សនៈវិជ្ជាច្បាប់និងការសិក្សាច្បាប់បរទេសដែរ។ ជាងនេះទៅទៀត នៅក្នុងការសិក្សាច្បាប់មានការផ្សាភ្ជាប់ទ្រឹស្តីមួយចំនួនកាលពីអតីតកាល ព្រមទាំងទិដ្ឋភាពសង្គម និងការវិវត្តនៃសេដ្ឋកិច្ចជាមូលដ្ឋាន។

២-៣. របៀបស្តាប់ត្រូបង្រៀន

១. ការរៀនត្រៀមមុន និង ការរំលឹកមេរៀន តើមួយណាល្អជាង?

ការសិក្សាបែបប្រព័ន្ធក្រេឌីតនៅតាមសាកលវិទ្យាល័យ បើសិនជាអ្នកសិក្សាមួយម៉ោងជាមួយគ្រូ អ្នកត្រូវការរៀនមុនគ្រូឲ្យបាន២ម៉ោង។ បើមានការណែនាំពីរបៀបវារៈបង្រៀនជាមុន នោះអ្នកត្រូវតែត្រៀមជាមុន។ ក្នុងការសិក្សាច្បាប់ បើសិនជាអ្នកបានរៀនត្រៀមជាមុន នោះអ្នកនឹងទទួលបានការយល់ដឹងជាវិជ្ជមានយ៉ាងធំធេង ហើយអ្នកអាចប្រើប្រាស់ពេលវេលានៅពេលរៀនជាមួយគ្រូយ៉ាងមានប្រយោជន៍ទៀតផងដែរ។ ថ្មីៗនេះ កាលវិភាគសិក្សា ប្លង់មេរៀន ត្រូវបានផ្សព្វផ្សាយឲ្យបានដឹងមុនថ្ងៃបង្រៀនផងដែរ ក្នុងគោលបំណងដើម្បីឲ្យនិស្សិតអាចមានពេលរៀនត្រៀមទុកមុន។

២. របៀបស្តាប់ក្នុងមុខវិជ្ជាច្បាប់

បើសិនជាអ្នកមនុស្សចូលចិត្តរៀនត្រៀមទុកមុន អ្នកនឹងមានចម្ងល់និងចំនុចមិនយល់ អ្នកនឹងអាចផ្តោតទៅការបង្រៀនរបស់គ្រូ។ រីឯ ការរំលឹកមេរៀនវិញគឺ អ្នកត្រូវយកចិត្តទុកដាក់ក្នុងការកត់ត្រាពេលគ្រូពន្យល់ ព្រមទាំងសរសេរកំណត់ត្រាដាក់ក្នុងឯកសារដែលគ្រូបានចែកនៅក្នុងម៉ោងសិក្សា។ ឧទាហរណ៍ ដូចជាការយកកម្រងច្បាប់ដាក់តាមខ្លួន និង ការយកចិត្តទុកដាក់ស្តាប់ថា តើគ្រូកំពុងនិយាយអំពីមាត្រាមួយណា។ ជាងនេះទៅទៀត អ្នកគួរតែដាក់ប្លង់មេរៀននៅក្បែរខ្លួនផងដែរ ស្តាប់បណ្តើរនិងធ្វើងផ្ទាត់ខ្លឹមសារ។

៣. តើគួរសរសេរកំណត់មេរៀនយ៉ាងណា?

របៀបក្នុងការកត់ត្រាត្រួសៗ គឺមានភាពខុសគ្នារវាងការរៀនត្រៀមទុកមុននិងការរំលឹកមេរៀន។ ចំពោះអ្នករៀនត្រៀមទុកមុន អ្នកគ្រាន់តែសរសេរបន្ថែមលើចំនុចដែលបានរៀនត្រៀម ហើយអាចត្រៀមសំណួរសួរនៅក្នុងម៉ោងគ្រូបង្រៀន។

រីឯ ចំពោះអ្នករំលឹកមេរៀនវិញ អ្នកត្រូវកត់ត្រាពេលគ្រូពន្យល់យ៉ាងស្វិតស្វាញជាមិនខាន។ ចំពោះអ្នកមិនមានសមត្ថភាពអាចរៀនត្រៀមជាមុនឬមិនចេះកត់ត្រាទុក គឺមិនអាចចាត់ទុកបាននោះ អ្នកគួរខ្វីកំណត់ហេតុរបស់មិត្តទៅសរសេរឡើងវិញ។

បច្ចេកទេសកត់ត្រាក្នុងម៉ោងរៀនឲ្យបានលឿននិងមិនខាតពេល ដូចជាការប្រើសរសេរអក្សរកាត់ ប្រើប្រាស់សញ្ញា និងលេខតំណាងជាដើម។ ខាងក្រោមជាឧទាហរណ៍ខ្លះៗនៃការសេរសេរកាត់ដើម្បីអាចកត់ត្រាត្រួសៗ។

X ដើមចោទ Y ចុងចម្លើយ

D តតិយជន (កូនបំណុល)

R ទណ្ឌីករណ៍

M ចំនុចវិជ្ជមាននៃគំនិត

DM ចំនុចអវិជ្ជមាននៃគំនិត

P ព្រះរាជាអាជ្ញា

J ចៅក្រម C តុលាការ

L មេធាវី S ជនសង្ស័យ

A ជនជាប់ចោទ

សម័យនេះភាគច្រើនគ្រូចែកឯកសារមេរៀន។ និស្សិតអាចសរសេរបន្ថែមពីលើនោះ ។ ប៉ុន្តែបើគ្រូមិនមានចែកឯកសារមេរៀនទេ និស្សិតអាចសុំកំណត់ហេតុមេរៀនរបស់រៀមច្បងយកមកចំលងដើម្បីមើលទុកមុនពេលស្តាប់គ្រូនិងអាចសរសេរកំណត់បន្ថែមពេលគ្រូបង្រៀន។

២-៤. រៀនសូត្រច្រើនពីម៉ោងរៀន

១. សុំជំនួយពីគ្រូឬរៀមច្បងគឺជាជម្រើសលឿន

ពេលដំបូងៗ សូមអ្នកព្យាយាមទៅសាលាស្តាប់គ្រូ ជាជាងចំណាយពេលវេលាអានសៀវភៅតែម្នាក់ឯងដោយគ្មានគោលដៅ។ គ្រូម្នាក់ៗ ច្បាស់ជាដឹងនូវការសិក្សាច្បាប់សម្រាប់និស្សិតនៅក្នុងដំហានដំបូងក្នុងមុខវិជ្ជានីមួយៗ។

មានពាក្យមួយឃ្លាថា «សួរម្តងអ្នកនឹងខ្មាសគេម្តង តែបើមិនសួរអ្នកនឹងខ្មាសគេមួយជីវិត»។ សិស្សមិនត្រូវខ្មាសអៀនក្នុងការសួរគ្រូឬរៀមច្បងជាច់ខាត។ អ្នកត្រូវប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធិភាពបំផុតជាមួយគ្រូដែលនៅជិតខ្លួន ក្នុងអំឡុងពេលរៀនកំពុងរៀននៅសាកលវិទ្យាល័យ។

២. មិនមែនទៅរៀនគ្រាន់តែស្តាប់គ្រូប៉ុណ្ណោះទេ

ការចូលរៀននៅក្នុងម៉ោងសិក្ខាប័នពិតជាមានសារៈប្រយោជន៍ណាស់ តែវាមិនអាចជួយដោះស្រាយបញ្ហាបានទាំងអស់នោះទេ។ ហេតុនេះ និស្សិតត្រូវប្រឹងប្រែងសួរសំណួរទៅគ្រូបន្ទាប់ពីម៉ោងរៀន។

គុណសម្បត្តិទី១នៃការសួរគ្រូ គឺដើម្បីទទួលដឹងនូវព័ត៌មានដែលគ្រូមិនបានយកមកជជែកនៅក្នុងម៉ោងរៀននិងស្វែងរកព័ត៌មានបន្ថែមដើម្បីត្រៀមប្រលងផង។ គុណសម្បត្តិទី២ គឺអាចធ្វើឲ្យគ្រូអាចចាប់អារម្មណ៍សំណួរនោះសម្រាប់ការបង្រៀនពេលក្រោយ។ យ៉ាងហោចណាស់ក៏មានតម្លៃសម្រាប់សិស្សប្អូនជំនាន់ក្រោយដែរ។ គុណសម្បត្តិទី៣ គឺអាចស្គាល់គ្រូបានជិតស្និត ពេលនោះអ្នកនឹងអាចទទួលបានព័ត៌មាននានា។ បំណាច់តែប្រើពេលវេលាដ៏មានតម្លៃឈានជើងទៅដល់ថ្នាក់រៀនហើយ អ្នកត្រូវព្យាយាមអស់ពីលទ្ធភាព។ ឧទាហរណ៍ថា នាពេលអនាគតអ្នកចង់ទៅរៀននៅបរទេសឬចង់បន្តរៀនថ្នាក់អនុបណ្ឌិត នោះអ្នកអាចសុំយោបល់ឬអាចសុំឲ្យគ្រូសរសេរលិខិតឧទ្ទេសនាមឲ្យបាន។

៣. របៀបសួរសំណួរ

ជាដំបូង អ្នកត្រូវដឹងថា គ្រូចូលចិត្តនិស្សិតដែលខិតខំប្រឹងប្រែងរៀនសូត្រ។ បើមានសិស្សណាចេះសួរនាំ គ្រូនឹងរីករាយស្វាគមន៍។ ហេតុនេះ បើសិនជាអ្នកចេះទៅសុំយោបល់ ឬ សួរសំណួរ គ្រូនឹងសប្បាយចិត្តជាមិនខាន។ ប៉ុន្តែ គ្រូម្នាក់ៗក៏មានភាពមមាញឹកច្រើន ហេតុនេះពេលអ្នកទៅសួរគ្រូ សូមពិចារណាឲ្យបានជិតដល់ថា តើអ្នកគួរសួរបែបណាទើបគ្រូសប្បាយចិត្តនឹងឆ្លើយ? អ្នកគួរទៅជួបគ្រូបន្ទាប់ពីម៉ោងរៀនទើបល្អ។ ភ្លាមៗបើអ្នកតេទូរស័ព្ទទៅគ្រូ ពេលខ្លះគ្រូកំពុងវល់ជាមួយអ្នកផ្សេង ឬ កំពុងប្រញាប់ប្រញាល់រៀបចំមេរៀនបង្រៀនក៏ថាបានទេ។ ចំពោះអត្ថន័យនៃសំណួរវិញ អ្នកគួរសួរសំណួរដែលទាក់ទងនឹងមេរៀនថ្មីៗ ឬមេរៀនមុនៗ។ អ្នកគួររៀបចំសំណួរជាមុន។ មានន័យថា សំណួរអ្នកមិនត្រូវមានលក្ខណៈអរូបិយទេ គួរតែជាសំណួរដែលមានលក្ខណៈជាក់ស្តែង។ គួរតែជាសំណួរមួយដែលអ្នកបានរៀនតែមិនទាន់យល់ ឬ ក៏គួរតែជាសំណួរដែលអ្នកបានស្រាវជ្រាវ គិតហើយ តែអ្នកមិនយល់ នោះទើបក្លាយជាសំណួរល្អ។

ពេលបង្រៀន គ្រូតែងតែឈរបង្រៀនមុខក្តារខៀន ពេលគ្រូនិយាយ អ្នកមិនគប្បីនិយាយរឿងមិនបានការឬរឿងឯកជនទេ។ គ្រូអាចមើលឃើញយ៉ាងច្បាស់ថានរណាកំពុងគេងលក់ និង នរណាកំពុងជជែកគ្នា។

៤. ស្វែងរកជំនួយដើម្បីលូតលាស់ទៅមុខទៀត

ចំពោះសិស្សដែលគ្រូបានស្គាល់មុខ ចង់ចេះដឹង នោះគ្រូនឹងឲ្យសៀវភៅខ្ចីដែលគ្មាននៅបណ្ណាល័យ ព្រមទាំងប្រាប់ពីប្រភពឯកសារផ្សេងៗទៀត។ បើចាំបាច់គ្រូនឹងណែនាំគ្រូប្រភពនៃការស្រាវជ្រាវផ្សេងទៀត ឬសរសេរលិខិតឧទ្ទេសនាមឲ្យអ្នកទៅស្រាវជ្រាវនៅស្ថាប័នស្រាវជ្រាវណាមួយ។

ប្រសិនបើអ្នកសរសេររបាយការណ៍តាមមុខវិជ្ជាណាមួយឬទាក់ទងនឹងការសិក្សានិងការស្រាវជ្រាវវិញ ពេលដែលអ្នកបានទទួលយោបល់ពីគ្រូណាម្នាក់ហើយ សូមយកលទ្ធផលនៃរបាយការណ៍នោះទៅប្រាប់គ្រូឲ្យបានដឹងផង។ គ្រូខ្លះនឹងជួយផ្តល់យោបល់រិះគន់កែតម្រូវ ហើយបើប៉ះចំគ្រូដែលចិត្តល្អជាងនេះ គាត់ក៏អាចរកកន្លែងណាមួយឲ្យអ្នកធ្វើបទបង្ហាញឲ្យអ្នកសិក្សាផ្សេងទៀតស្តាប់ផងក៏ថាបាន។

៥. ស្វែងរកជំនួយពីរៀមច្បង

បើសិនជាអ្នកសុំយោបល់ពីរៀមច្បងដែលរៀនមិនសូវចេះ វាហាក់បីដូចជាមនុស្សខ្វាក់កំពុងដឹកដៃមនុស្សខ្វាក់។ ក្រុមនិស្សិតខ្លះមានបណ្តាញរៀមច្បងនិងលោកគ្រូដែលជាមេធាវីឬជាអ្នកបានប្រលងជាប់វិជ្ជាជីវៈច្បាប់។ អ្នកត្រូវទៅជួបមនុស្សបែបនោះ ទើបពួកគាត់អាចផ្តល់ចម្លើយដែលមានន័យគ្រប់គ្រាន់បាន។ ជាងនេះទៅទៀត ពេលរៀនសម្រាប់ប្រលងវិជ្ជាជីវៈ មិនសូវមានគ្រូណាជួយកែឲ្យអ្នកទេ ហេតុនេះអ្នកអាចទៅសាកសួរពីរបៀបដោះស្រាយលំហាត់ពីរៀមច្បងនិងឲ្យរៀមច្បងជួយកែតម្រូវ។ ទាំងនេះគឺជាវិធីក្នុងដំណាក់កាលដំបូងនៃការរៀនច្បាប់ដែលមានសារៈប្រយោជន៍បំផុត។

ជំពូកទី៣

បញ្ជីសៀវភៅសម្រាប់និស្សិតច្បាប់អានជាមូលដ្ឋានគ្រឹះ

៣-១. នីតិសាធារណៈ:

១. ម៉ូរីស ហ្គៃយ៉ា និងផ្សេងទៀត. *នីតិវិជ្ជធម្មនុញ្ញកម្ពុជា*. ភ្នំពេញ៖ ហ្វូណន, ២០០៥។

២. ម៉ូរីស ហ្គៃយ៉ា និងផ្សេងទៀត. *សេចក្តីផ្តើមនៃនីតិកម្ពុជា*. ភ្នំពេញ៖ ហ្វូណន, ២០០៥។

៣. ឈុន ណារ៉េត. *សេចក្តីផ្តើមនីតិវិជ្ជធម្មនុញ្ញ*. ភ្នំពេញ៖ រោងពុម្ពដាវ៉ា, ២០១៦។

៤. សុខ យ៉ាន និង សុខ ចិន្តា. *នីតិវិជ្ជធម្មនុញ្ញ*. ភ្នំពេញ, ២០១៥។

៥. សេង ប៊ុនធឿន. *រដ្ឋធម្មនុញ្ញនិងការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជា*. ភ្នំពេញ, ២០១៥។

៦. សាយ បូរី. *វិទ្យាសាស្ត្ររដ្ឋបាល*. ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១៥។

៧. សាយ បូរី. *នីតិវិជ្ជបាលទូទៅ*. ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០១២។

៣-២. នីតិឯកជន

៨. EWMI. *ច្បាប់អចលនវត្ថុនៅកម្ពុជា ទិដ្ឋភាពជារួម*. ២០១២។

៩. កុយ នាម. *ច្បាប់ក្រុមហ៊ុន*. ២០១៦។

១០. ហ៊ែល ចំរើន. *នីតិការងារ*. ២០០៥។

១១. ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និងភាគទី២*. ២០១២។

៣-៣. ប្រវត្តិសាស្ត្រ នយោបាយ ទស្សនវិជ្ជា

១២. ត្រឹង ងា. *ប្រវត្តិសាស្ត្រកម្ពុជា*. ភ្នំពេញ៖ រោងពុម្ពអប់រំ, ១៩៧៣។

១៣. ដេវិឌ ឆាណ្ឌលឺរ. *ប្រវត្តិសាស្ត្រខ្មែរ*. ភ្នំពេញ៖ មជ្ឈមណ្ឌលខេមរសិក្សា, ២០០០។

១៤. វ៉ាន់ឌី កាអុន. *ទិដ្ឋភាពខ្លះៗនៃទស្សនវិជ្ជា*. ភ្នំពេញ៖ ពន្លឺ, ២០១៣។

៣-៤. វិធីសាស្ត្រស្រាវជ្រាវ

១៥.ហាប់ ផល្លី. *គុណធម៌នៃការស្រាវជ្រាវ*. ២០១៨។

១៦. ញាន វណ្ណៈ. *មូលដ្ឋានគ្រឹះនៃភាពជាអ្នកច្បាប់*. ២០១៤។

១៧. Kai Hauerstein, *Introduction to Legislative Drafting References & Techniques*, Permanent Secretariat of the Committee for Legal and Judicial Reform (Ministry of Justice) & Konrad-Adenauer-Stiftung, 2016.

៣-៥. អត្ថបទពិចារណា

១៨. មាស បូរ៉ា និង លោក នូ ចន្ថា. *"អំពីទោសប្រហារជីវិត"* ២០១៨។

១៩. តាំង រតនា. *"បេះដូងភ្នំវែក ប្រលោមលោកបែបប្រវត្តិសាស្ត្រ" ២០១៩*។